# របាយការណ៍
# បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ និងទិសដៅការងារឆ្នាំ ២០២៣
# របស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

## សេចក្តីផ្តើម

ការអភិវឌ្ឍជនបទ គឺជាសកម្មភាពដែលដើរតួនាទីយ៉ាងសំខាន់ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍជាតិ និងការកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ក្នុងអាណត្តិទី ៦ របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការរៀបចំ និងអនុវត្តសកម្មភាពអភិវឌ្ឍន៍ជនបទចម្រុះ ដែលជាសកម្មភាពប្រទាក់ក្រឡា និងអន្តរវិស័យ សំដៅកែប្រែទីជនបទ និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋនៅជនបទឱ្យមានភាពប្រសើរឡើង។

ក្នុងនោះដែរ ការអភិវឌ្ឍសហគមន៍ គឺជាតម្រូវការចាំបាច់ក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទ និងបានចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងសមត្ថភាពសហគមន៍មូលដ្ឋាន។ ម្យ៉ាងទៀត ការងារអភិវឌ្ឍន៍សហគមន៍ គឺជាយន្តការគន្លឹះមួយ ដែលធ្វើសកម្មភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ នៅមូលដ្ឋានសំដៅធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ឥរិយាបថ និងផ្នត់គំនិតរបស់សហគមន៍ជនបទ ដើម្បីឱ្យការអភិវឌ្ឍមួយមានភាពជាម្ចាស់ និងប្រកបដោយនិរន្តភាព។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ជានាយកដ្ឋានជំនាញ ដែលបានចូលរួមយ៉ាងសកម្មក្នុងការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅជនបទ តាមរយៈការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ការអភិវឌ្ឍភូមិចម្រុះ ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន និងការបង្កើនសមត្ថភាពសហគមន៍ដើម្បីកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយក្នុងសហគមន៍។

ក្នុងនោះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍មានការិយាល័យចំណុះចំនួន ០៥ រួមមាន ការិយាល័យកិច្ចការទូទៅ ការិយាល័យអភិវឌ្ឍន៍មូលដ្ឋាន ការិយាល័យសន្តិសុខស្បៀង ការិយាល័យអប់រំក្រៅប្រព័ន្ធ និងការិយាល័យមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ ព្រមទាំងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ។ ក្នុងឆ្នាំ ២០២២ នេះ នាយកដ្ឋានបានអនុវត្តការងារ ហើយទទួលបានលទ្ធផលដូចខាងក្រោម៖

## I. សមិទ្ធផលសម្រេចបាន

### ១. ការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)

គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ជាគណៈកម្មាធិការមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងជារចនាសម្ព័ន្ធអភិវឌ្ឍន៍នៅថ្នាក់ភូមិ មានតួនាទីជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការដឹកនាំ និងសម្របសម្រួលការងារអភិវឌ្ឍន៍ភូមិ។ ដើម្បីឱ្យ គ.អ.ភ យល់ដឹងពីតួនាទី ភារកិច្ចរបស់ខ្លួន និងមានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពអភិវឌ្ឍន៍ភូមិប្រចាំឆ្នាំ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តបានយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាព គ.អ.ភ ជាលទ្ធផលក្នុងឆ្នាំ ២០២២ រួមមានៈ

### ក. ការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)

ក្នុងឆ្នាំ ២០២២ នេះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍បានគាំទ្រដល់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ១១ ក្នុងការពង្រឹងសមត្ថភាព គ.អ.ភ ស្តីពី ការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ និងសញ្ញាណចលនាភូមិថ្មី បានចំនួន ៣០ វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ៦០០ នាក់ ស្រី ២១១ នាក់ មកពី ១៦៩ ភូមិ។ ដោយឡែក មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបានចុះពង្រឹងតួនាទី ភារកិច្ច គ.អ.ភ បានចំនួន ៦៩ វគ្គ មានសិក្ខាកាមសរុបចំនួន ២ ១៩២ នាក់ ស្រី ៧៧៤ មកពី ៣៧៣ ភូមិ។

### ខ. ការធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)

សម្រាប់ការធ្វើបច្ចុប្បន្នភាព គ.អ.ភ ក្នុងឆ្នាំ ២០២២ នេះ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តបានធ្វើបច្ចុប្បន្នភាពបានចំនួន ៥៨៣ ភូមិ ២៩ ឃុំ ៨៣ ស្រុក ហើយមានសមាជិក គ.អ.ភ សរុបចំនួន ៤ ២៨៥ នាក់ ស្រី ១ ៣១៧ ក្នុងនោះ ភូមិមានសកម្មភាពចំនួន ១ ៥៣៤ ភូមិ ភូមិមានអង្គការគាំទ្រចំនួន ២១០ ភូមិ។

### ២. ការអភិវឌ្ឍភូមិចម្រុះ

ការគាំទ្រសកម្មភាពអភិវឌ្ឍន៍ភូមិចម្រុះ គឺជាការឆ្លើយតបទៅនឹងតម្រូវការចាំបាច់មូលដ្ឋានរបស់ប្រជាពលរដ្ឋជនបទ ដើម្បីបង្កលក្ខណៈឱ្យសហគមន៍មានលទ្ធភាពធ្វើការអភិវឌ្ឍបានដោយខ្លួនឯង។ សកម្មភាពអភិវឌ្ឍន៍ភូមិចម្រុះ គឺជាការអន្តរាគមន៍ក្នុងរយៈពេលខ្លី សម្រាប់ឱ្យប្រជាពលរដ្ឋយល់ដឹងពីអត្ថប្រយោជន៍នៃ ការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចគ្រួសារ។ ហើយសកម្មភាពនេះបានរួមចំណែកយ៉ាងសកម្មក្នុងការធ្វើឱ្យ ប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងភូមិនីមួយៗនៅជនបទ តាមរយៈការផ្តល់ជូននូវ ពូជរុក្ខជាតិ ពូជសត្វ និងស្រះចិញ្ចឹមត្រីជាដើម។ ជាលទ្ធផលក្នុងឆ្នាំ ២០២២ នាយកដ្ឋានបានគាំទ្រសកម្មភាពអភិឌ្ឍន៍ភូមិចម្រុះរួមមាន កូនឈើហូបផ្លែ ពូជបន្លែចម្រុះ និងស្រះគ្រួសារ លើភូមិគោលដៅចំនួន ០៥ ភូមិ នៃខេត្តចំនួន ០៥ ខេត្ត (ខេត្ត/តំបន់) គឺៈ

– ភូមិទួលវិហារមានជ័យ ឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
    - ផ្តល់ស្រះគ្រួសារ ៥ម x ៦ម x ២.៥ម បានចំនួន ១០ ស្រះ ដល់គ្រួសារសរុប ១០ គ្រួសារ
    - កូនឈើហូបផ្លែចម្រុះបានចំនួន ៨០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ

- ពូជបន្លែចម្រុះចំនួន ១ ៨០០ កញ្ចប់ ដល់គ្រួសារសរុប ១០០ គ្រួសារ។

– ភូមិបុះញិញ ឃុំកូនសត្វ ស្រុកទឹកឈូ ខេត្តកំពត

- ផ្តល់ស្រះគ្រួសារ ៥ម x ៦ម x ២.៥ម បានចំនួន ១០ ស្រះ ដល់គ្រួសារសរុប ១០ គ្រួសារ
- កូនឈើហូបផ្លែចម្រុះបានចំនួន ៨០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ
- ពូជបន្លែចម្រុះចំនួន ១ ៨០០ កញ្ចប់ ដល់គ្រួសារសរុប ១០០ គ្រួសារ។

– ភូមិគោកចាន់ ឃុំតាសោម ស្រុកអង្គរជុំ ខេត្តសៀមរាប

- ផ្តល់ស្រះគ្រួសារ ៥ម x ៦ម x ២.៥ម បានចំនួន ១០ ស្រះ ដល់គ្រួសារសរុប ១០ គ្រួសារ
- កូនឈើហូបផ្លែចម្រុះបានចំនួន ៨០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ
- ពូជបន្លែចម្រុះចំនួន ១ ៨០០ កញ្ចប់ ដល់គ្រួសារសរុប ១០០ គ្រួសារ។

– ភូមិកោះជ្រឹម ឃុំអូរម្រេះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង

- ផ្តល់ស្រះគ្រួសារ ៥ម x ៦ម x ២.៥ម បានចំនួន ១០ ស្រះ ដល់គ្រួសារសរុប ១០ គ្រួសារ
- កូនឈើហូបផ្លែចម្រុះបានចំនួន ៨០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ
- ពូជបន្លែចម្រុះចំនួន ១ ៨០០ កញ្ចប់ ដល់គ្រួសារសរុប ១០០ គ្រួសារ។

– ភូមិដូនយូ ឃុំជាខ្លាង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង

- ផ្តល់ស្រះគ្រួសារ ៥ម x ៦ម x ២.៥ម បានចំនួន ១០ ស្រះ ដល់គ្រួសារសរុប ១០ គ្រួសារ
- កូនឈើហូបផ្លែចម្រុះបានចំនួន ៨០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ
- ពូជបន្លែចម្រុះចំនួន ១ ៨០០ កញ្ចប់ ដល់គ្រួសារសរុប ១០០ គ្រួសារ។

### ៣. ការបង្កើនសន្តិសុខស្បៀងជាលក្ខណៈគ្រួសារ

គម្រោងលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារប្រចាំឆ្នាំ ២០២២ បានអនុវត្តសកម្មភាពដូចខាងក្រោម៖

– បើកវគ្គបណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត បានចំនួន ០៥ វគ្គ មានសិក្ខាកាមចូលរួមចំនួន ១០០ នាក់ ស្រី ៨២ នាក់ ក្នុងនោះ

- ខេត្តសៀមរាប ចំនួន ០៣ វគ្គ មានសិក្ខាកាមសរុបចំនួន ៦០ នាក់ ស្រី ៤៧ នាក់ មកពី ០៣ ភូមិ
- ខេត្តកែប ចំនួន ០២ វគ្គ មានសិក្ខាកាមសរុបចំនួន ៤០ នាក់ ស្រី ៣៥ នាក់ មកពី ០២ ភូមិ

- ផ្តល់ពូជបន្លែចម្រុះដល់គ្រួសារសហគមន៍ចំនួន ៣១៥ គ្រួសារ ក្នុងខេត្តគោលដៅចំនួន ០២ គឺ
    - នៅភូមិ ដាក់ការ តាយ៉ែក ត្រាវបាក់ ឃុំតាយ៉ែក និងភូមិសំរោងជើង សំរោងត្បូង និងស្ទឹង ឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប សរុបចំនួន ២១០ គ្រួសារ។
    - នៅភូមិកោះសោម អំពែង អន្លោល ឃុំអន្លោល និងភូមព្រៃតកុយ រនេស ឃុំពងទឹក ស្រុកដំណាក់ចង្អើ ក្រុងកែប ខេត្តកែប សរុងចំនួន ១០៥ គ្រួសារ។
- ផ្តល់សម្ភារធ្វើរោងជីកំប៉ុស្តដល់គ្រួសារសហគមន៍ចំនួន ៣១៥ គ្រួសារ ក្នុងខេត្តគោលដៅចំនួន ០២ គឺ
    - នៅភូមិ ដាក់ការ តាយ៉ែក ត្រាវបាក់ ឃុំតាយ៉ែក និងភូមិសំរោងជើង សំរោងត្បូង និងស្ទឹង ឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប សរុបចំនួន ២១០ គ្រួសារ។
    - នៅភូមិកោះសោម អំពែង អន្លោល ឃុំអន្លោល និងភូមព្រៃតកុយ រនេស ឃុំពងទឹក ស្រុកដំណាក់ចង្អើ ក្រុងកែប ខេត្តកែប សរុងចំនួន ១០៥ គ្រួសារ។

## ៤. ការអប់រំក្រៅប្រព័ន្ធ

ការិយាល័យអប់រំក្រៅប្រព័ន្ធ នៅក្នុងឆ្នាំ ២០២២ បានបើកវគ្គបណ្តុះបណ្តាលការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍ បានចំនួន ០៥ វគ្គ ដែលមានចំនួនសរុប ១០០ នាក់ ស្រី ៣៤ នាក់ មកពី ១០ ភូមិ ក្នុងនោះ៖

- ខេត្តប៉ៃលិន ចំនួន ០២ វគ្គ មានសិក្ខាកាមសរុបចំនួន ៤០ នាក់ ស្រី ១២ នាក់ មកពី ០៤ ភូមិ
- ខេត្តបន្ទាយមានជ័យ ចំនួន ០៣ វគ្គ មានសិក្ខាកាមសរុបចំនួន ៦០ នាក់ ស្រី ២២ នាក់ មកពី ០៦ ភូមិ។

## ៥. ការពង្រឹងសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ

ក្នុងឆ្នាំ ២០២២ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ បានបើកវគ្គបណ្តុះបណ្តាលក្នុងមជ្ឈមណ្ឌលស្តីពី បច្ចេកទេសផលិតសាប៊ូ ការគ្រប់គ្រងផលិតផលក្រោយប្រមូលផល ការអភិវឌ្ឍសហគមន៍ ការដាំដំណាំ និងការចិញ្ចឹមសត្វ បានចំនួន ០៩ វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ៣៤០ នាក់ ស្រី ១៦១ នាក់។ ក្នុងនោះដែរ មជ្ឈមណ្ឌលបានសហការអនុវត្តគម្រោងរវាងអង្គការម៉ារីយាអ៊ីនធើណាសិនណាល់ (Merry Year International) ដើម្បីធ្វើការបណ្តុះបណ្តាលបន្ថែមបានចំនួន ០៧ វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ១៣៩ នាក់ ស្រី ៥៧ នាក់។

## ៦. ការពង្រឹងសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ និងខេត្តតាកែវ

នៅឆ្នាំ ២០២២ មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តកំពង់ស្ពឺ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តតាកែវ បានបើកវគ្គបណ្តុះបណ្តាលនៅក្រោមជ្ឈមណ្ឌលស្តីពី ជួសជុលអណ្តូងស្នប់ ដាំដំណាំ និងចិញ្ចឹមសត្វ បានចំនួន ៣៤ វគ្គ មានសិក្ខាកាមសរុបចំនួន ៦៨០ នាក់ ស្រី ២៨៣ នាក់ ក្នុងនោះ៖

- មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តតាកែវ បានបើកវគ្គបណ្តុះបណ្តាលបានចំនួន ១៩ វគ្គ សិក្ខាកាមចំនួន ៣៨០ នាក់ ស្រី ១៩៧ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលបានចំនួន ១៥ វគ្គ សិក្ខាកាមចំនួន ៣០០ នាក់ ស្រី ៨៦ នាក់។

### ៧. គម្រោងហិរញ្ញប្បទានថវិកាដៃគូអភិវឌ្ឍន៍

ក្នុងឆ្នាំ ២០២២ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ បានធ្វើកិច្ចសហប្រតិបត្តិការអនុវត្តគម្រោងដែលជាហិរញ្ញប្បទានពីសាធារណរដ្ឋកូរ៉េ តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការកូរ៉េ (KOICA) និងមជ្ឈមណ្ឌលចលនាភូមិថ្មីកូរ៉េ ចំនួន ០២ គម្រោងគឺ៖

- គម្រោង **"ការកសាងភូមិសន្តិភាព តាមរយៈការអភិវឌ្ឍសហគមន៍ជនបទចម្រុះ"** (Building Peace Village Through Integrated Rural Community Development) មានរយៈអនុវត្តគម្រោងចំនួន ០៥ ឆ្នាំ (២០២២-២០២៦) ជាមួយនឹងថវិកាសរុបចំនួន ១០ 000 000 ដុល្លារអាមេរិក តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការកូរ៉េ (KOICA) ដែលនឹងអនុវត្តគម្រោងនៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន។ គម្រោងមានគោលបំណង លើកកម្ពស់លក្ខខណ្ឌរស់នៅ និងផ្តល់អាទិភាពដល់សហគមន៍ជនបទ បង្កើននិរន្តរភាពប្រាក់ចំណូលកសិកម្ម និងអភិបាលកិច្ចល្អនៃការអភិវឌ្ឍជនបទ។ ជាលទ្ធផលក្នុងឆ្នាំ ២០២២ នេះ គម្រោងបានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងបង្កើតគណៈកម្មការគ្រប់គ្រង និងអនុវត្តគម្រោងចុះសិក្សាលទ្ធភាពដើម្បីជ្រើសរើសភូមិគោលដៅអនុវត្តគម្រោង និងកំពុងដំណើរការជ្រើសរើសក្រុមការងារគ្រប់គ្រងគម្រោង។
- គម្រោង **"ភូមិគំរូចលនាភូមិថ្មី"** (Saemaul Undong Model Villagers Project) មានរយៈអនុវត្តគម្រោងចំនួន ០៥ ឆ្នាំ (២០២២-២០២៦) ជាមួយនឹងថវិកាសរុបចំនួន ៩០០ 000 ដុល្លារអាមេរិក តាមរយៈមជ្ឈមណ្ឌលចលនាភូមិថ្មីកូរ៉េ ដែលនឹងអនុវត្តគម្រោងនៅភូមិចំនួន ០៤ ក្នុងឃុំព្រៃរំដួល ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ គម្រោងមានគោលបំណង លើកកម្ពស់លក្ខខណ្ឌរស់នៅ និងផ្តល់អំណាចដល់សហគមន៍ជនបទ បង្កើននិរន្តរភាពកសិកម្ម និងការពង្រឹងសមត្ថភាព។ ជាលទ្ធផលក្នុងឆ្នាំ ២០២២ នេះ គម្រោងបានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោង បង្កើតគណៈកម្មការគ្រប់គ្រង និងអនុវត្តគម្រោង និងបានរៀបចំសំណើផែនការសកម្មភាពអនុវត្តសកម្មភាពរបស់ភូមិ។

## II. បញ្ហាប្រឈម

តាមរយៈសមិទ្ធិផលដែលទទួលបានពីការអនុវត្តការងារក្នុងខែកន្លងមក នាយកដ្ឋានបានកត់សម្គាល់ឃើញថា មានបញ្ហាប្រឈមមួយចំនួនបានផ្តល់ការលំបាកក្នុងដំណើរការអនុវត្តសកម្មភាព ក៏ដូចជាកត្តារាំងស្ទះក្នុងការអភិវឌ្ឍសហគមន៍ជនបទមានដូចខាងក្រោម ៖

- ជីវភាពខ្វះខាតធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនចំណាកស្រុក ដែលឱ្យប៉ះពាល់ដល់ដំណើរការនៃការអនុវត្តសកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋាន
- ថវិកាសម្រាប់បណ្តុះបណ្តាលពុំទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍នៅឡើយ
- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័ន ឬអង្គការមួយចំនួន មិនប្រើប្រាស់ គ.អ.ភ ហើយបានបង្កើត និងប្រើប្រាស់ជនបង្គោលផ្សេងៗ
- ពុំសូវមានសមាសភាព គ.អ.ភ ជាស្រ្តី ដែលសារាចរណែនាំ ជំរុញសមាសភាពជាស្ត្រីចូលរួមឱ្យបានច្រើន
- សកម្មភាពគាំទ្រការអភិវឌ្ឍភូមិចម្រុះ និងសន្តិសុខស្បៀង ដែលមានការផ្តល់ពូជរុក្ខជាតិ ពូជសត្វ ស្រះគ្រួសារ និងសម្ភាររោងជីកំប៉ុស្តជាដើម ត្រូវបានដាក់ក្នុងផែនការលទ្ធកម្មរួមរបស់ក្រសួង ធ្វើឱ្យសកម្មភាពនេះពិបាកក្នុងការអនុវត្ត ឬមិនអាចអនុវត្តបាន។

III. **ទិសដៅការងារ**

- អនុវត្តសកម្មភាពពង្រឹងសមត្ថភាព គ.អ.ភ តាមផែនការថវិកាតាមកម្មវិធីឆ្នាំ ២០២៣
- សម្របសម្រួលជាមួយមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ឱ្យបន្តខិតខំស្វែងរកកិច្ចសហការ និងការគាំទ្រពីគម្រោងកម្មវិធី និងអង្គការនានា ក្នុងការពង្រឹងសមត្ថភាព គ.អ.ភ
- បន្តគាំទ្រដល់គម្រោងអភិវឌ្ឍន៍ភូមិចំរុះ ដើម្បីអភិវឌ្ឍន៍ទៅជាភូមិគំរូ
- បន្តបណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត
- បន្តគាំទ្រដល់គ្រួសារសហគមន៍នូវ ពូជបន្លែចម្រុះ និងសម្ភារធ្វើរោងជីកំប៉ុស្ត
- បន្តបណ្តុះបណ្តាលស្តីពីការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍
- បន្តតាមដានការអនុវត្តសកម្មភាពបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ
- សម្របសម្រួល និងសហការអនុវត្តគម្រោងហិរញ្ញប្បទានថវិកាដៃគូអភិវឌ្ឍន៍។

## សេចក្តីសន្និដ្ឋាន

ការអភិវឌ្ឍសហគមន៍ គឺជាផ្នែកមួយនៃសកម្មភាពសកម្មភាពរួម ឬវិស័យមួយរួមចំណែកក្នុងយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលក្នុងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតាមជនបទ និងការកាត់បន្ថយគម្លាតរវាងតំបន់ជនបទ និងទីក្រុងទាក់ទងជាមួយលក្ខខណ្ឌទូទៅក្នុងជីវភាពសង្គមប្រចាំថ្ងៃ។

ក្នុងនោះដែរ ក្រោមការដឹកនាំគាំទ្រ និងចង្អុលបង្ហាញពី **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ក៏ដូចជាថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីឆ្លើយតបទៅនឹងទស្សនវិស័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ "**សហគមន៍មានលក្ខខណ្ឌជីវិតរស់នៅសមរម្យប្រកបដោយសេចក្តីថ្លៃថ្នូរ និងមានសមត្ថភាពអាចគ្រប់គ្រង ចាត់ចែង និងដឹកនាំការងារអភិវឌ្ឍន៍បានដោយខ្លួនឯង**" នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

បានប្រើប្រាស់ថវិកាតាមកម្មវិធី និងកំណត់នូវសូចនាករ ហើយអនុវត្តនូវសកម្មភាពអភិវឌ្ឍន៍ចម្រុះ ដែលមានការពង្រឹងសមត្ថភាព និងការផ្តល់នូវជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីរួមចំណែកលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជននៅតាមសហគមន៍ជនបទ៕